# ដំណាំត្រឡាច

## I. លក្ខណៈរុក្ខសាស្ត្រ និង ប្រភពដើម

ដាំណាំត្រឡាចត្រូវបានដាំដុះ និង ប្រើប្រាស់រាប់រយឆ្នាំកន្លងមកហើយ ជាពិសេសនៅក្នុងតំបន់អាស៊ីយើង ។ ដាំណាំនេះវាស្ថិតនៅក្នុងគ្រួសារ Cucurbitaceae អនុក្រុម Benincaseae លំដាប់ Benineasa និងមានឈ្មោះវិទ្យាសាស្ត្រហៅថា Benincasa hispida ឈ្មោះធម្មតាហៅថាWax gourd or Ash Gourd។





ត្រឡាចចែកចេញជាពីរប្រភេទគឺត្រឡាចស្រូវនៅក្នុងផ្លែមានគ្រាប់តូចមូលផ្លែតូចហើយមូលចំពោះត្រឡាចប្រេងវិញមានផ្លែធំទ្រវែងគ្រាប់ធំសំប៉ែត ហើយអាចរក្សាទុកបានយូរជាងត្រឡាចស្រូវចំពោះផ្លែទុំ ។ អំពីលក្ខណៈរុក្ខសាស្ត្រសំខាន់វារបស់វាគឺដើមស្លឹកផ្កា មានលក្ខណៈប្រហាក់ប្រហែលគ្នាទៅនឹងប្រភេទផ្សេងៗនៃគ្រួសារដូចគ្នា ។ ដើមមានសភាពជាវល្លិភ្ជាប់ដោយថ្នាំងចន្លោះថ្នាំងប្រវែង ៨ទៅ១៥ ស.ម ហើយអាចលូតវារតោងឡើងដើមរុក្ខជាតិឯទៀតនៅក្បែរវា ឬក៏ធ្វើរដែលធ្វើឱ្យវាតោងឡើងជូនកាលគេដាំឱ្យវា វារនៅលើដីផ្ទាល់គឺថ្នាំងរបស់វាមានលទ្ធភាពដុះចេញឫសឫសទាំងនោះមានសារៈសំខាន់ គឺ ជួយបឺតយកសារធាតុ ចិញ្ចឹមទៅជួយឱ្យមានការលូតលាស់បានឆាប់រហ័ស។ ស្លឹកមានសភាពឆ្លាស់គ្នាគឺឈមនឹងដើមតភ្ជាប់ដោយទងស្លឹកត្រឡាចជាស្លឹកជាប់មិនផែកចេញជាសំណុំស្លឹកឡើយស្លឹកដើមផ្កាផ្លែ គឺមានបន្លាខ្លីៗលេចចេញពីស្បែកខាងក្រៅ ។

តារាងអាហាររូបត្ថម្ភ

ក្នុងទម្ងន់១០០gដែលបរិភោគបាននៃផ្លែត្រឡាច

| ឈ្មោះបន្លែ | កាឡូរី | | ជាតិទឹក % | កាបូនអ៊ីដ្រាត % | ផេះ g | ការ៉ូតែន mg | វីតាមីន B mg | | វីតាមិន c | ធាតុរ៉ែ | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | ស្យាមីន | ផ្លាវីន | | Ca | Fe |
| ត្រឡាច | 10 | 96.7 | 1.9 | 0.4 | 0.1 | 00 | 0.06 | 0.06 | 1 | 30 | 0.8 |

- ***អំពីផ្កា:*** *ដំណាំនេះផ្ការួមដើមគឺផ្កាញីនិងឈ្មោលនៅដើមតែមួយផ្កាមានត្របក៥និងមានស្រទប ៥ ហើយមានថង់លំអងចំនួនច្រើនដែលផ្ទុកលំអង ផ្កាឈ្មោល និង ផ្កាញី* សម្រាប់លក្ខណៈបន្តពូជ ។

ផ្លែរបស់វាគឺមានសភាពមូលទ្រវែងខ្លះមូលខ្លី លក្ខណៈពិសេសផ្លែរបស់វាមានម្សៅជាអ្នកការពារស្បែកត្រឡាចឱ្យធន់កំដៅ និងការប្រែប្រួលរបស់ធម្មជាតិ ។ ជាទូទៅដំណាំនេះអាចលូតលាស់បានប្រវែងពី ៨ទៅ ១៥ម ហើយអាចរស់នៅច្រើនឆ្នាំ ។

## I. លក្ខខណ្ឌបរិស្ថានរបស់ដំណាំត្រឡាច

កត្តាបរិស្ថាន ត្រូវបានរាប់បញ្ចូលជាកត្តាសំខាន់សម្រាប់ដំណាំត្រឡាចដូចជា ពន្លឺសីតុណ្ហភាពដីរបបខ្យល់ សំណើមបរិយាកាសនិងកត្តាទឹកភ្លៀង ។

**កត្តាសីតុណ្ហភាពនិងពន្លឺ:** ជាកត្តាមួយចូលរួមក្នុងដំណើរនៃអន្តរអំពើដូចជារស្មីសំយោគនិងដំណាកដង្ហើមដើម្បីផលិតឡើងនូវភាពបៃតងក្លរ៉ូភីលនិងកាបូអ៊ីត្រាត ។





***កត្តាដី:*** ដីជាកត្តាចាំបាច់សម្រាប់ការដុះលូតលាស់ដីសំបូរទៅដោយជាតិមមោកព្រមទាំងសារធាតុចិញ្ចឹមផ្សេងៗទៀតជាពិសេសធាតុរ៉ែ ។ ចំពោះដំណាំត្រឡាចជាដំណាំមួយរាប់បញ្ចូលក្នុងក្រុមធន់ទ្រាំទៅនឹងជាតិអាស៊ីដនៃដី។ ដីដែលសមស្រប គឺប្រភេទដីល្បាប់ ល្បាយខ្សាច់ ដីក្រហមតំបន់ភ្នំនិងដីតាមតំបន់វាលរាបមួយចំនួនដែលមាន PH ជាមធ្យមចន្លោះពី ៥,០ ទៅ៦,៣ ចំពោះ PH ទាបជាង ៥ ធ្វើឱ្យផ្លែរីកធំធាត់មិនបានល្អបន្ថយចំនួននៃការចេញផ្កានិងបន្ថយសមត្ថភាពនៃការស្វ័យលំអង ធ្វើឱ្យត្រឡាចទុំមុនអាយុឬជួនកាលត្រឡាចអាចងាប់ទៅវិញដោយកង្វះសារធាតុចិញ្ចឹម ។ ឫសរបស់ត្រឡាចមានលទ្ធភាពចាក់ចូលទៅក្នុងដីបានពី ៦៨ទៅ ១០០ស.ម ជាពិសេសគឺលើប្រភេទដីខ្សាច់ ។

- ***របបខ្យល់ សំណើម ទឹកភ្លៀង:*** ដំណាំប្រភេទនេះមិនត្រូវការខ្យល់បក់ខ្លាំងក្នុងអំឡុងពេលកំពុងលូតលាស់កាលណាសីតុណ្ហភាពឡើងខ្ពស់ខ្យល់បក់ខ្លាំងសំណើមដីមិនគ្រប់គ្រាន់ វាធ្វើឱ្យរឹតតែបាត់បង់សំណើមបន្ថែមទៀត និងម្យ៉ាងទៀតអាចធ្វើឱ្យត្រឡាចដុះលូតលាស់ខ្សោយព្រោះពេលខ្យល់បក់ខ្លាំងរុក្ខជាតិក៏បាត់បង់ជាតិទឹកខ្លាំងដោយ សាររំហួតចំហាយទឹកពេលរំហួតចំហាយទឹកខ្លាំងរុក្ខជាតិត្រូវបិទនូវប្រព័ន្ធស្តូម៉ាក់របស់ស្លឹកដើម្បីការពារនូវការបាត់បង់ជាតិទឹកពីក្នុងកោសិកាពេលនោះស្លឹករុក្ខជាតិឡើងរញ្ជួមដៃដែលបោះតោង ក៏លែងលូតលាស់ធ្វើឱ្យត្រួយរមូរ។ គេមិនអាចដាំវានៅតំបន់ដែលមានខ្យល់បក់ខ្លាំងនិងដោយធម្មជាតិផ្ទាល់នោះទេគឺគេតែងតែធ្វើប្រព័ន្ធការពារដូចជារបាំងខ្យល់សំណាញ់នៅក្នុងតំបន់មាន

ខ្យល់ខ្លាំងក្នុងអំឡុងពេលលូតលាស់របស់ដំណាំ ។

អំពីកត្តាសំណើមៈ សំណើមបរិយាកាសមានទំនាក់ទំនងយ៉ាងខ្លាំងទៅនឹងការលូតលាស់ពេលសំណើមបរិយាកាសឡើងក្នុងចន្លោះពី ៧០-៨០ % អាចធ្វើឱ្យ ដំណាំលូតលាស់លឿនព្រោះសំណើមបរិយាកាសមានទំនាក់ទំនងទៅនឹងសីតុណ្ហភាពព្រមទាំងពន្លឺផងដែរ។ នៅពេលសំណើមបរិយាកាសចុះទាបចន្លោះពី៤៥ទៅ ៥៥% ធ្វើឱ្យអាកាសធាតុក្តៅហួតហែងនិងអាំងតង់ស៊ីតេពន្លឺខ្លាំងធ្វើឱ្យដំណាំបន្ថយការលូតលាស់ព្រមទាំងបង្កឱ្យមានកត្តាចង្រៃទៀតផង ។

ចំពោះសំណើមដីវិញដំណាំត្រឡាចត្រូវការសំណើមដីពេលលូតលាស់ដំបូងគឺចន្លោះពី៧០ទៅ៧៥% ពេលចេញផ្ការហូតដល់ផ្លែគឺត្រូវ ការទឹកខ្លាំងពី ៧៥ទៅ៨៥% ។

អំពីទឹកភ្លៀងៈ ទឹកភ្លៀងជាកត្តាមួយដែលមានទំនាក់ទំនងទៅនឹងសំណើម របស់ដីនៅពេលដាំដុះនិងការស្រោចស្រពត្រឡាចមិនត្រូវការភ្លៀងខ្លាំងដូចដំណាំឯទៀតឡើយភ្លៀងធ្វើឱ្យដំណាំត្រឡាចរលួយឬសជ្រុះផ្កាគេអាចដាំនៅរដូវភ្លៀង បានដោយធ្វើផ្ទើរឬទុកឱ្យវាវារឡើងស្រឡះផុតពីដីទើបបន្ថយការជ្រុះផ្កាទឹកភ្លៀងអាចបង្កជម្ងឺផ្សិតនៅក្នុងផ្កាព្រមទាំងរលួយគល់ពេលសំណើមដីឡើងខ្លាំង ។

## I. ការដាំដុះ

គេអាចដាំដំណាំត្រឡាចលើដីច្រើនប្រភេទ ហើយវិធីដាំដុះក៏អាស្រ័យទៅតាមប្រភេទពូជប្រភេទដីនិងរដូវកាលផងដែរ ។



## ១. អំពីរដូវកាលដាំដុះ

ដំណាំត្រឡាចអាចដាំដុះបានពេញមួយឆ្នាំគឺ អាស្រ័យទៅតាមតំបន់ដាំដុះនៅក្នុងប្រទេសកម្ពុជាយើងគេបែងចែករដូវដាំដុះត្រឡាចជាពីររដូវ គឺ រដូវទឹកសំរកភាគច្រើនតែនៅតំបន់ទំនាបមាត់ទន្លេសាបឬតាមបណ្តោយមាត់ទន្លេមេគង្គចាប់ផ្តើមពីខែវិច្ឆិកា និងប្រមូលផលនៅខែធ្នូ រហូតដល់ខែកុម្ភៈ ។ នៅតំបន់ខ្ពង់រាបភាគច្រើនគេដាំនៅរដូវវស្សាព្រម ទាំងតំបន់នេះភាគច្រើនគេដាំឱ្យវារឡើងផ្ទើរខ្ពស់ផុតពីដី ។

## ២. ការរៀបចំដី



ពូកវីរ៉ុសយ៉ាងលឿនផងដែរដែរ ។

*ធាតុផូស្វ័រ (P)* ធ្វើឱ្យដើមរឹងមាំបង្កើតសារធាតុខ្សាច់នៅពីលើស្លឹកដើមផ្លែពិសេសសម្រាប់ជួយឱ្យប្រព័ន្ធឫសមានសភាពរឹងមាំពង្រីកកោសិកា ខ្ចីៗ នៅត្រង់ចន្លោះពន្លកដូចជាចន្លោះដើមផ្នែកខ្ចីៗនៃផ្លែជាដើម។ ផូស្វ័រធ្វើឱ្យផ្លែរីកលូតលាស់បានឆាប់រហ័សបង្កឱ្យសារធាតុចិញ្ចឹមក្នុងដីមានដំណើរការល្អ ។

*ប៉ូតាស្យូម (K)* ប៉ូតាស្យូមមានតួនាទីធ្វើឱ្យមានសកម្មភាពល្អក្នុងការចិញ្ចឹមសរីរាង្គ។ ធ្វើឱ្យឫសរឹងមាំជួយឱ្យរុក្ខជាតិមានពណ៌ខៀវរលើបស្រស់ ។ ក្រៅពីនោះ K ធ្វើឱ្យមានរស់ជាតិកាន់តែប្រសើរឡើង ។

**វិធីប្រើប្រាស់ជីមានៈ**

កំប៉ុស្តទ្រាប់បាតមុនពេលដាំចំនួន៥ ទៅ ៧ តោន/ហ.ត

- ជី ដេអាប៉េ(DAP)ទ្រាប់បានមុនពេលដាំចំនួន ២០០គ.ក្រ/ហ.ត
- ជីអ៊ុយរ៉េ ៤៦ % ដាក់ក្រោយដាំ១០ថ្ងៃ ចំនួន៥០ គ.ក្រក្នុង១ ហ.ត លាយទឹកស្រោច ។
- ជី ១៥,១៥,១៥ដាក់ក្រោយដាំ២៥ថ្ងៃចំនួន១៥០ គ.ក្រ/ហ.ត ដាក់ចំងាយ២៥ម ពីគល់ ។
- ជីអ៊ុយរ៉េ ៤៦%ដាក់ពេលចេញផ្កា១០០ % ចំនួន៦០គ.ក្រ/ហ.ត ។
- ជី ១៥,១៥,១៥ ដាក់ក្រោយប្រមូលផលបាន ២លើកចំនួន៥០ -៦០ គ.ក្រ/ហ.ត ។



- ដាំលើករងទទឹងរង៣០០ ស.ម ចន្លោះ ជួរ ២៥០ស.ម ចន្លោះគុម្ព ១៥០ស.ម
- ដាំដាក់ផ្ទើរមិនលើករងទទទឹងផ្ទើរ៣៣០ ស.ម ចន្លោះគុម្ព ១៥០ ស.ម ចំនួនដើមក្នុងគុម្ពគឺ ២ទៅ៣ ដើម ។

ជាទូទៅមុនពេលដាំគេកាប់ជារណ្តៅនៅលើរងហើយដាក់ជីកំប៉ុស្តិចំនួន ០,៥គ.ក្រ លាយជាមួយដី១៥,១៥,១៥ ឬ១៨,៤៦,០ ចំនួន១០០ទៅ ១៥០ក្រាម ក្នុងមួយរណ្តៅ ។

**៤.ការស្រោចស្រព**

ដំណាំត្រឡាចមិនត្រូវការទឹកខ្លាំងដូចដំណាំឪឡឹក ឬ ត្រសក់ចំណារឡើយវាត្រូវការទឹកមធ្យមដូចល្ពៅ និងត្រសក់ស្រូវដែរ ។ គេអាចធ្វើការស្រោចស្រពបានច្រើនវិធីដូចជាៈ តាមរយៈទឹកភ្លៀងកំពស់ភ្លៀងមធ្យមប្រចាំខែ ៨០ ទៅ១២០ ម.ម ជាការល្អស្រោចដោយបញ្ចូលទឹកតាមចន្លោះជួរគឺមួយអាទិត្យពី ១ទៅ២លើកតាមសភាពដីនិងសីតុណ្ហភាព ។

**៥.ការប្រើប្រាស់ជី**

*ធាតុអាសូត(N)* ដំណាំត្រឡាចត្រូវការធាតុអាសូតដូចដំណាំឯទៀតដែរ ប៉ុន្តែវាត្រូវការនៅក្នុងដំណាក់កាលចាប់ផ្តើមចេញផ្កា ព្រោះធាតុអាសូតធ្វើឱ្យត្រឡាចដុះពន្លកទងបានលឿនហើយភាពបៃតងខ្ចីរបស់វាកាន់តែធ្វើឱ្យការទទួលយកពន្លឺនិងការបញ្ជូនជាតិទឹកកាន់តែ រហ័ស ។ ប៉ុន្តែអាសូតធ្វើឱ្យត្រឡាចឆាប់ទទួលរងជម្ងឺ

DAP ចំនួន ៥គ.ក្រ ឬជី១៥,១៥,១៥ ចំនួន២ គ.ក្រកំបោរស ២គ.ក្រនិងថ្នាំ Furadan3H ចំនួន២០០ក្រាម លាយបញ្ចូលគ្នាឱ្យសព្វទើបច្រកចូលក្នុងឧបករណ៍ទាំងនេះ ។

ចំពោះគ្រាប់ពូជដែលត្រូវយកមកបណ្តុះគេត្រូវដាក់ហាលថ្ងៃរយៈពេល ២ម៉ោងក្រោយមកទើបយកទៅត្រាំទឹកលាយជាមួយថ្នាំសម្លាប់ផ្សិត ដូចជា: Zineb-maneb ដូចជាManigroនិង Orthocide ២ក្រាម ក្នុងទឹក១លីត្រ រយៈពេល២០-៣០នាទីទើបយកមកបណ្តុះ ។ ដើម្បីដាំ ១ហ.តគេត្រូវប្រើប្រាស់គ្រាប់ពូជអស់ចំនួន៣,៤ ទៅ ៥ គ.ក្រត្រឡាចមានទម្ងន់គ្រាប់៥០ ទៅ៦០ ក្រ.ក្នុងចំនួន១០០គ្រាប់ ។ ក្រោយពីបណ្តុះរយៈពេល ៨ទៅ ១០ថ្ងៃត្រឡាចមានសន្លឹកកំណើតចំនួន២នោះគេអាចយកកូនត្រឡាច ទៅដាំបានមុនដាំត្រូវ បាញ់ថ្នាំលាយជាមួយសូលុយស្យុងថ្នាំផ្សិតការពារទើបអាចដាំបាន ។

**ខ.ការដាំដុះ**

ការដាំដុះដំណាំត្រឡាចគេចែកចេញជាច្រើនវិធី គឺដាំដោយប្រើប្រព័ន្ធស្រោចស្រព និងមិនប្រើប្រព័ន្ធស្រោចស្រព ។ នៅតាមតំបន់ ទន្លេមេគង្គរដូវសំរកគេដាំដោយមិនប្រើប្រព័ន្ធស្រោចស្រពទេ គឺដីល្បប់តាមមាត់ទន្លេគេដាំឱ្យវាដុះលូតលាស់ដោយប្រើសំណើមដីនិងសំណើមបរិយាកាស ។ នៅតំបន់នេះដែរគេដាំដោយប្រើប្រព័ន្ធស្រោចស្រពគឺ របៀបដាំភាគច្រើនគ្របចំបើងក្រោយពេលដាំហើយដោយប្រើចន្លោះជួរនិងចន្លោះគុម្ពដូចតទៅ:



- ដាំលើករងទទឹងរង៣០០ ស.ម ចន្លោះ ជួរ ២៥០ស.ម ចន្លោះគុម្ព ១៥០ស.ម
- ដាំដាក់ផ្ទើរមិនលើករងទេទទឹងផ្ទើរ៣៣០ ស.ម ចន្លោះគុម្ព ១៥០ ស.ម ចំនួនដើមក្នុងគុម្ពគឺ ២ទៅ៣ ដើម ។

ជាទូទៅមុនពេលដាំគេកាប់ជារណ្តៅនៅលើរងហើយដាក់ជីកំប៉ុស្តិចំនួន ០,៥គ.ក្រ លាយជាមួយជី១៥,១៥,១៥ ឬ ១៨,៤៦,០ ចំនួន ១០០ ទៅ ១៥០ ក្រាម ក្នុងមួយរណ្តៅ ។

**៤.ការស្រោចស្រព**

ដំណាំត្រឡាចមិនត្រូវការទឹកខ្លាំងដូចដំណាំឪឡឹក ឬ ត្រសក់ចំណារឡើយវាត្រូវការទឹកមធ្យមដូចល្ពៅ និងត្រសក់ស្រូវដែរ ។ គេអាចធ្វើការស្រោចស្រពបានច្រើនវិធីដូចជា: តាមរយៈទឹកភ្លៀងកំពស់ភ្លៀងមធ្យមប្រចាំខែ ៨០ ទៅ១២០ ម.ម ជាការល្អស្រោចដោយបញ្ចូលទឹកតាមចន្លោះជួរគឺមួយអាទិត្យពី ១ទៅ២លើកតាមសភាពដីនិងសីតុណ្ហភាព ។

**៥.ការប្រើប្រាស់ជី**

*ធាតុអាសូត(N)* ដំណាំត្រឡាចត្រូវការធាតុអាសូតដូចដំណាំឯទៀតដែរ ប៉ុន្តែវាត្រូវការនៅក្នុងដំណាក់កាលចាប់ផ្តើមចេញផ្កា ព្រោះធាតុអាសូតធ្វើឱ្យត្រឡាចដុះពន្លកទងបានលឿនហើយភាពបៃតងខ្ចីរបស់វាកាន់តែធ្វើឱ្យការទទួលយកពន្លឺនិងការបញ្ជូនជាតិទឹកកាន់តែ រហ័ស ។ ប៉ុន្តែអាសូតធ្វើឱ្យត្រឡាចឆាប់ទទួលរងជម្ងឺ

## IV. អំពីជម្ងឺនិងសត្វល្អិត

### ១. អំពីជម្ងឺសំខាន់ៗ

ក.ជម្ងឺក្រាម្សៅលើស្លឹក: ជម្ងឺប្រភេទនេះបំផ្លាញដំណាំយ៉ាងខ្លាំងក្លាជាពិសេសនៅរដូវត្រជាក់ស្ងួតគ្មានភ្លៀង និង តំបន់ចំការមិនមានអាកាសធាតុបរិបូរណ៍ពិសេសចំការនៅក្បែរព្រៃឈើ ។ រោគសញ្ញាដំបូង គឺគេឃើញចំណុចផ្សិតសៗលើផ្ទៃស្លឹកផ្នែកខាងលើខ្នង ស្លឹកក្រោយមកផ្សិតទាំងនោះរីករាលដាលចេញទូទាំងចំការតែម្តងធ្វើឱ្យស្លឹកប្រែពីពណ៌បៃតងទៅពណ៌ត្នោត ហើយក្រៀម ជ្រុះស្ព័រហុយពេញចំការ ។ ការប្រើថ្នាំប្រភេទគារាពតKarathane Bavistin, Captan កំរិត ១ក្រ លាយទឹក១លីត្រ ឬ ១៥ ក្រ = ១៥ លីត្រទឹកបាញ់នៅពេលវាទើបនឹងកើតឡើង ។

ខ.ជម្ងឺផ្សិតពពាលក្រោមស្លឹក: ជម្ងឺនេះកើតឡើងដោយពួកផ្សិតច្រើនកើតឡើងនៅលើពួកដំណាំដូចជាត្រសក់ ឪឡឹកឃ្លោក ល្ពៅជាពិសេសកើតឡើងនៅពេលសំណើមបរិយាកាសឡើងខ្ពស់ និងមានភ្លៀងធ្លាក់ពិសេសនៅរដូវប្រាំងជាហេតុបង្កឱ្យកើតជម្ងឺនេះយ៉ាងឆាប់រហ័ស។ ដំបូងលេចចេញស្នាមពណ៌ពព្រុះ អុចៗលើផ្ទៃស្លឹកក្រោយមកវាពពាលពណ៌លឿងឬត្នោតខ្ចីក្រោយមកវារីករាលដាលចំណុចទាំងនោះជាប់គ្នាធ្វើឱ្យស្លឹករមួរជាប់គ្នាហើយជ្រុះស្លឹកតែម្តង ។ ការរីករាលដាលពេញចំការយ៉ាងឆាប់រហ័សដោយសារទឹក ខ្យល់ ។ ការប្រើប្រាស់ថ្នាំ Dithane M45 (Maneb) ឬ និងរៀកំរិត២០ ក្រទឹក១៥ លីត្របាញ់ពេញផ្ទៃចំការ



## ៦.ការកំចាត់ស្មៅជ្រុំដីពូនគល់ នឹងកាត់ខ្នែង

ជាទូទៅការងារដាំដុះត្រូវផ្សារភ្ជាប់ និងបច្ចេកទេសថៃទាំងដូចជា: ការពូនរងសំអាតស្មៅការកាត់មែកជាដើម ។ ទាំងនោះជាវិធីសាស្ត្រដែលធ្វើឱ្យដំណាំដុះលូតលាស់បានល្អ ។

ក. វិធានការកំចាត់ស្មៅ: ការកំចាត់ស្មៅគេអាចធ្វើឡើងបានច្រើនវិធីមុនពេលដាំគេអាចព្រោចថ្នាំដូចជា Paraquateចំនួន ១៨គ.ក្រ/ហ.ត ហើយរាស់លប់មុនពេលដាំនិងក្រោយពីដាំបានចំនួន១០ ទៅ១៥ថ្ងៃគេបាញ់ថ្នាំ Parawuate ទឹកចំនួន ២០០០ CC លាយទឹក ២៥៩ ទៅ ៣០០ លីត្រ១ ហ.ត តែហាមបេះកូនដំណាំដោយប្រើវិធីក្រុងកូនដំណាំទើបបាញ់ថ្នាំ ។ ចំពោះវិធីសាស្ត្រ ធម្មតាក្រោយពិដាំបានរយៈពេល ១០ ទៅ ១៥ ថ្ងៃគេជ្រុំដីកំចាត់ស្មៅលើកទី១ លើកទី២ និងលើកទី៣វាអាស្រ័យទៅនឹង តំបន់ដាំដុះតែហាមការជ្រុំដោយកាយដីដែលជាហេតុបណ្តាលឱ្យដាច់ឫស ។

ខ.ការជ្រុំដីពូនគល់និងកាត់ខ្នែង: គេអាចជ្រុំឱ្យផុស ហើយពូនគល់ឱ្យជិតឬក៏លប់ដីឱ្យបាន ២ទៅ៣ ថ្នាំងក្បែរដីប្រយោជន៍ឱ្យ ថ្នាំនោះដុះចេញឫសថ្មី ។ មុននឹងជ្រុំគល់គេកាត់ស្លឹកនោះក្បែរគល់ចេញហើយពត់ដើមឱ្យជារង្វង់មូលទើបលុបដីពីលើក្រោយមកទើបកាត់ត្រួយដើមចេញ ឱ្យដើមដែលកប់នៅក្នុងដីដុះខ្នែងចេញនិងចេញផ្កា ។

## ២. អំពីសត្វល្អិតសំខាន់ៗ មាន ៖

ក. ពពួកអុចជញ្ជក់: ចៃគ្រប់ប្រភេទមមាចមមង់ រុយស រុយទិចផ្លែ ។

ខ. ពពួកកាត់ដើមសីស្លឹកមាន:ដង្កូវហ្វូងដង្កូវចោះផ្លែដង្កូវស៊ីផ្កាដង្កូវកាត់ដើមដង្កូវមូរស្លឹកដង្កូវស៊ីរុលក្នុងស្លឹក ។

គ. វិធានការការពារនិងកំចាត់ការកំចាត់ស្មៅ កាត់ស្មៅដែលស៊ុយទ្រុបចោលខ្លះដើម្បីបន្ថយជំរកសត្វល្អិត ជ្រើសរើសរដូវដាំដុះកាត់បន្ថយការកើនឡើងនៃពពួកសត្វល្អិតចង្រៃជ្រើសរើសពូជធន់ទ្រាំអាយុកាលលូតលាស់ខ្លី ។

**វិធានការគីមី**

ប្រើប្រាស់ថ្នាំពុលដូចជា:Azodrin Diazinon Mevinphos Desice Supermethrin Cumicidin Sumithion និង Dupan ៧០ % បាញ់១សប្តាហ៍ ២លើក។





មុនពេលរីករាលដាល ២ ដងក្នុងមួយសប្តាហ៍ ។

គ. ជម្ងឺជាំស្លឹក ឬ ផ្លែ: ជម្ងឺនេះកើតឡើងដោយសារ មេរោគ Colletortrichum SP បំផ្លាញលើផ្លែស្លឹកដើមស្ទើរគ្រប់រុក្ខជាតិ ដំបូងគេឃើញចំណុចរទុះៗលើផ្ទៃស្លឹកចំណុចអុចរទុះៗទាំងនេះកាន់តែរីករាលដាលធំឡើងៗហើយមានពណ៌ច្រេះស្ងួតផ្ទៃរង្វង់ជុំវិញកាលណាកើតជម្ងឺនេះ ស្លឹកលែងលូតលាស់ តែបើកើតលើ ផ្លែវិញធ្វើឱ្យផ្លែត្រឡាចអុចស្រឡាកលើផ្ទៃអាចបណ្តាលឱ្យរលួយពេលទុំ។គេប្រើថ្នាំផ្សិតប្រភេទ Dithane M-45 (Maneb)ឬក៏Dithane Z -៧៨ (Xineb)ចំនួន៥-៧ថ្ងៃម្តងពេលពិនិត្យឃើញរោគសញ្ញាជម្ងឺកំរិត០,២% ។

ឃ. ជម្ងឺរលួយនឹងពុកឫស ឬដើម: ជម្ងឺប្រភេទនេះដំបូងធ្វើឱ្យរុក្ខជាតិទន់ឫសក្រោយមកធ្វើឱ្យពុកឫសប្រែពណ៌ខ្មៅ ។ ការកើតជម្ងឺនេះរហ័សបណ្តាលមកពីសំណើមបរិយាកាសនិងសំណើមដីខ្ពស់។ មេរោគ Fusarium Oxyspo-rum wilt បណ្តាលរបស់ពួក Niveum វាបំផ្លាញគ្រប់ដំណាក់កាលរបស់ដំណាំធ្វើឱ្យដំណាំស្វិតស្រពោនភ្លាមៗ ក្រោយពីបំផ្លាញមានលក្ខណ:ប្រហែលនឹងជម្ងឺBacterial wilt និងជំងឺ Suothern Bight ដែរ ។ គេប្រើថ្នាំ Captan or Hexocap កំរិត២០ទៅ ៣០ក្រាមទឹក ២០លីត្រ បាញ់ ២ ទៅ ៣ លើកក្នុងមួយអាទិត្យបន្ថយការស្រោចទឹកនិងការប្រើប្រាស់ជីអាសូត ។

ង.ជម្ងឺវីរុសដែលកើតលើដំណាំត្រឡាច: ជម្ងឺនេះពុំមានលទ្ធភាពព្យាបាលឡើយតែគេមានវិធានការការពារ និង កំចាត់សត្វល្អិតជាភ្នាក់ងារចម្លងដោយវិធានការគីមីពួកចៃមមាចទ្រីពអាចធ្វើដំណាំជៀសផុតពីការកើតជម្ងឺវិរុស។

- ការប្រមូលផលសម្រាប់កែច្នៃ: គឺគេទុកផ្លែត្រឡាចឱ្យទុំឡើងម្សៅពេញទូទាំងផ្លែគេបេះផ្លែត្រឡាចទាំងនោះយកមក ទុកសម្រាប់យកសាច់មកកែច្នៃធ្វើត្រឡាចក្រៀមឬដំណាប់ត្រឡាចដែលអាចយកមកធ្វើជា គ្រឿងបង្អែមផ្សេងៗគឺ ក្រោយដាំ រយៈពេល ៨០ ទៅ៩០ថ្ងៃ ។

- ការប្រមូលផលសម្រាប់ទុកពូជ: មានលក្ខណៈដូចការប្រមូលផលសម្រាប់កែច្នៃដែរ គេបេះផ្លែត្រឡាចមករក្សាទុករយៈ ១០-១៥ថ្ងៃ ក្រោយមកវះយកគ្រាប់ត្រឡាចមកត្រាំទឹករយៈពេល ២ ទៅ៣ ថ្ងៃ ឱ្យរលួយសាច់ទើបលាងទឹកឱ្យស្អាតហើយដាក់ហាលថ្ងៃរយៈពេល ២-៣ ថ្ងៃ ទើបអាចយកមករក្សាទុកបាន ។





## V.ការប្រមូលផល

ការប្រមូលផលត្រឡាចខុសពិការប្រមូលផលដំណាំឪឡឹកគេអាចបែងចែកជា ២ ផ្នែកនៃការប្រមូលផល ។

- ការប្រមូលផលជាបន្លែស្រស់ គេអាចប្រមូលផលផ្លែបន្លែខ្ចីក្រោយពីត្រឡាចចេញផ្កាបានចំនួន១៨ទៅ២២ថ្ងៃ ក្រោយដាំរយៈពេល៧០ទៅ៨០ថ្ងៃ ។ គេបេះផ្លែខ្ចីសម្រាប់យកទៅធ្វើទៅជាបន្លែស្រស់ ។ នៅប្រទេសជឿនលឿនគេដាំសម្រាប់ធ្វើទឹកត្រឡាចកំប៉ុងគឺការដាំដុះជាទ្រង់ទ្រាយធំរាប់ពាន់ហ.ត គេប្រមូលផលដោយម៉ាស៊ីនដូចជានៅប្រទេសចិន ឥណ្ឌូនេស៊ីឬ សហរដ្ឋអាមេរិក

